**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ១៣១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងបំណុលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤/អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ . _**

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវ គោលការណ៍ណែនាំ គោលនយោបាយ យុទ្ធសាស្ត្រ មុខងារគ្រប់គ្រង យន្តការគ្រប់គ្រង និងបទប្បញ្ញត្តិនានាស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ២ . _**

អនុក្រឹត្យនេះមានគោលបំណង ៖

១- ធានាថា ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានអនុវត្តដោយអនុលោមតាមច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ស្ដីពីមូលបត្ររដ្ឋ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

២- កំណត់ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងបំណុលសាធារណៈប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឲ្យបាននូវ ៖

- ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច
- ការឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទាន ដោយរក្សាហានិភ័យ និងបន្ទុកសេវាបំណុលសាធារណៈឲ្យនៅកម្រិតអប្បបរមា
- ការរួមចំណែកអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣- កំណត់គោលដៅ និងគោលការណ៍នៃការខ្ចីប្រាក់ពីគេ និងនៃការធានារបស់រដ្ឋ

៤- កំណត់គោលការណ៍រៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។

៥- កំណត់គោលការណ៍រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ។

៦- កំណត់គោលការណ៍រៀបចំរបាយការណ៍គណនេយ្យ ស្តីពីបន្ទុកសេវាបំណុលសាធារណៈ ស្របតាមចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ។

៧- ធានាលើការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋឲ្យបានត្រឹមត្រូវ តាមរយៈការធ្វើប្រតិភូកម្ម និងការត្រួតពិនិត្យរាល់សកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ៣ .–**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើប្រតិបត្តិការ ដូចខាងក្រោម ៖

១- ការផ្តល់សិទ្ធិអំណាច ការធ្វើប្រតិភូកម្មអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រងបំណុលសាធារណៈ

២- ការខ្ចីប្រាក់ពីក្នុង និង ក្រៅប្រទេស

៣- ការបោះផ្សាយមូលបត្ររដ្ឋលើទីផ្សារហិរញ្ញវត្ថុក្នុងប្រទេស

៤- ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ

៥- ការឱ្យប្រាក់គេខ្ចី

៦- ការធានា និងការកត់ត្រាកាតព្វកិច្ចបំណុលជាយថាហេតុ

៧- ការវិនិយោគដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា

៨- ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ

៩- កិច្ចបញ្ជិកា និងការរៀបចំរបាយការណ៍បំណុលសាធារណៈ ។

**មាត្រា ៤ .–**

និយមន័យនៃវាក្យស័ព្ទសម្រាប់ប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដោយសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

# ជំពូកទី ២
## សិទ្ធិអំណាច ការធ្វើប្រតិភូកម្មអំណាច និងការទទួលខុសត្រូវ

**មាត្រា ៥ . _**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចចាត់ចែងលើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ៦ . _**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងស្ថិតក្រោមអំណាចនាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការវិនិយោគ ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា ការឲ្យប្រាក់គេខ្ចី និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ ។

លក្ខខណ្ឌផ្នែកហិរញ្ញវត្ថុ និង ទំហំទឹកប្រាក់នៃការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

ការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ៧ . _**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិធ្វើប្រតិភូកម្មអំណាចដល់មន្ត្រីមួយ ឬច្រើនរូប ដើម្បីបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ ។ ការធ្វើប្រតិភូកម្មអំណាចត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៨ . _**

វៀរលែងតែមានបដិប្បញ្ញត្តិដោយច្បាប់ និងស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចខ្ចីប្រាក់ពីគេសម្រាប់បម្រើឲ្យគោលដៅ ដូចខាងក្រោម ៖

១- ហិរញ្ញប្បទានលើគម្រោងអាទិភាព ដែលមានកំណត់ក្នុងកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល

២- បន្តពង្រឹងការគ្រប់គ្រងគោលនយោបាយថវិកា
៣- ផ្តល់ឲ្យសហគ្រាសសាធារណៈខ្ចី
៤- ផ្តល់ឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុខ្ចី ដោយធ្វើការពិគ្រោះយោបល់ជាមួយធនាគារជាតិនៃកម្ពុជាជាមុន
៥- ហិរញ្ញប្បទានលើឱនភាពថវិកា
៦- ទទួលបាននូវរូបិយប័ណ្ណបរទេស
៧- ហិរញ្ញប្បទានលើបំណុលដែលដល់ឥណប្រតិទាន
៨- ផ្តល់ឲ្យរដ្ឋបរទេសខ្ចី ។

**មាត្រា ៩ . _**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិបត្តិការណាមួយដែលនាំឱ្យកើតមានបំណុលសាធារណៈបាន លុះត្រាតែធ្វើឡើងស្របតាមគោលការណ៍ និងលក្ខខណ្ឌកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១០ . _**

រាល់ការដោះស្រាយកាតព្វកិច្ចបំណុលសាធារណៈរបស់រដ្ឋ ត្រូវធ្វើឡើងតាមគោលការណ៍ស្មើភាពចំពោះគ្រប់ម្ចាស់បំណុលទាំងអស់ ។

វៀរលែងតែមានបដិប្បញ្ញត្តិដោយច្បាប់ រាជរដ្ឋាភិបាលមិនត្រូវយកធនធាន ឬទ្រព្យសម្បត្តិរដ្ឋ ឬចំណូលរដ្ឋ ធ្វើជាកម្មវត្ថុនៃការបញ្ចាំក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការផ្តល់ការសន្យាឬការធានាណាមួយ ដែលនាំឱ្យកើតកាតព្វកិច្ចបំណុលបានទេ ។ ធនធាន ឬទ្រព្យសម្បត្តិរដ្ឋ ឬចំណូលរដ្ឋ ត្រូវទទួលបាននូវការការពារដោយរាជរដ្ឋាភិបាលពីការរឹបអូស ឬការឃាត់ទុកផ្សេងៗ ។

**មាត្រា ១១ . _**

រាជរដ្ឋាភិបាល ត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានភារកិច្ចរៀបចំនិងត្រួតពិនិត្យ

ការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ និងពិនិត្យយល់ព្រមលើយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈមុននឹងដាក់សុំការសម្រេចពីនាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ត្រូវមានសមាសភាពមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ។

**មាត្រា ១២ .** _

រាល់ការងារបច្ចេកទេសនិងប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋ អាចអនុវត្តដោយធនាគារជាតិនៃកម្ពុជា ក្នុងនាមជាភ្នាក់ងារគ្រប់គ្រងមូលបត្ររដ្ឋរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៣ .** _

រាជរដ្ឋាភិបាលត្រូវបង្កើតមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ដើម្បីគ្រប់គ្រងការបោះផ្សាយនិងការទូទាត់សងមូលបត្ររដ្ឋ និងការងារពាក់ព័ន្ធផ្សេងទៀត ។

អនុញ្ញាតឲ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់ឱ្យធ្វើប្រតិបត្តិការ និងគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មអំណាចពាក់ព័ន្ធនឹងប្រតិបត្តិការ និងការគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ជូនទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

**មាត្រា ១៤ .** _

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ដើម្បីពិនិត្យ ពិភាក្សា និងលើកយោបល់ជូនគណៈកម្មាធិការចម្រុះសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ ស្តីពីការរៀបចំក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ព្រមទាំងកិច្ចប្រតិបត្តិការនិងការគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ។

**មាត្រា ១៥ .** _

គណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវមានសមាជិកយ៉ាងច្រើន ៩រូប ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែងតាំងសមាជិកជាមន្ត្រីជាន់ខ្ពស់ ដែលមានសមាសភាពមកពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា ក្រសួង និងស្ថាប័នពាក់ព័ន្ធ ផ្អែកតាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងប្រធានស្ថាប័នពាក់ព័ន្ធ ។

គណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវដឹកនាំដោយអគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវមានលេខាធិការដ្ឋានសម្រាប់តាមដានត្រួតពិនិត្យលើប្រតិបត្តិការពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្ររដ្ឋ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

**មាត្រា ១៦ . _**

អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវទទួលបន្ទុកលើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋមិនអាចជួញដូរបាន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧ . _**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ជូនរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា តាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៣
## បំណុលសាធារណៈ ការខ្ចីប្រាក់ពីគេ និងការធានា

**មាត្រា ១៨ . _**

រាល់ការខ្ចីប្រាក់ពីគេ ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋលើទីផ្សារក្នុងប្រទេស ការបោះផ្សាយនិងការដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារអន្តរជាតិ ការធានា និងកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវធ្វើឡើងស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងច្បាប់ស្តីពីមូលបត្ររដ្ឋ ។

រាល់ការងារបច្ចេកទេស និងប្រតិបត្តិការពាក់ព័ន្ធនឹងការខ្ចីប្រាក់ពីគេ ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋលើទីផ្សារក្នុងប្រទេស ការបោះផ្សាយនិងការដាក់

លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារអន្តរជាតិ ការធានា និងកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ឬប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ និងតាមការសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១៩ .-**

រាល់ការដកសាច់ប្រាក់ ការចាត់ចែង និងការទូទាត់សេវាបំណុលសាធារណៈក្រៅប្រទេស ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌ និងនីតិវិធី ដែលមានចែងក្នុងកិច្ចព្រមព្រៀងឥណទាន និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋលើទីផ្សារក្នុងប្រទេស ត្រូវអនុវត្តតាមច្បាប់ស្តីពីមូលបត្ររដ្ឋ ។

ការបោះផ្សាយនិងការដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារអន្តរជាតិ ត្រូវអនុវត្តតាមសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀង ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។ ការចាត់ចែង និងការទូទាត់សេវាបំណុលនៃសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចព្រមព្រៀង ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២០ .-**

ស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងនាមរាជរដ្ឋាភិបាល គឺជាអ្នកផ្តល់ការធានាជាលាយលក្ខណ៍អក្សរលើកិច្ចសន្យា ឬកិច្ចព្រមព្រៀង ឬគម្រោងដែលអនុវត្តដោយសហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

រាល់សហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការធានាពីរាជរដ្ឋាភិបាល ត្រូវទូទាត់កម្រៃធានា និងកម្រៃពាក់ព័ន្ធផ្សេងទៀតជូនរាជរដ្ឋាភិបាល ។

គោលនយោបាយកំណត់កម្រៃធានា និងកម្រៃពាក់ព័ន្ធផ្សេងទៀត ព្រមទាំងកាតព្វកិច្ចរបាយការណ៍របស់សហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការធានា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រាល់ការចរចាពាក់ព័ន្ធនឹងការធានា ត្រូវធ្វើឡើងដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយកកម្រៃពីការធានា និងកម្រៃពាក់ព័ន្ធផ្សេងទៀត សម្រាប់ជាគុណប្រយោជន៍នៃចំណូលថវិការដ្ឋ និងការគ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ២១ . _**

សហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការធានាពីរាជរដ្ឋាភិបាល តែការធានានោះត្រូវបានដកហូតមកវិញ ដោយសារការខកខានមិនបានបំពេញកាតព្វកិច្ចសេវាបំណុលតាមកិច្ចព្រមព្រៀង ត្រូវមានកាតព្វកិច្ចទូទាត់ជូនរាជរដ្ឋាភិបាលនូវរាល់ការចំណាយពាក់ព័ន្ធរួមមាន ៖ សេវាបំណុល ប្រាក់ពិន័យ និងចំណាយពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ២២ . _**

រាល់ការឱ្យប្រាក់គេខ្ចី ត្រូវធ្វើឡើងស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្រោមទម្រង់ជាកិច្ចព្រមព្រៀងឥណទានដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាមរាជរដ្ឋាភិបាល ឬតាមការប្រទានសិទ្ធិ ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

រាល់ឥណទាយិក ដែលទទួលបានហិរញ្ញប្បទានឥណទានពីរាជរដ្ឋាភិបាល ត្រូវទូទាត់សេវាបំណុលជូនរាជរដ្ឋាភិបាល ។

គោលនយោបាយកំណត់លក្ខខណ្ឌនៃការឲ្យប្រាក់គេខ្ចី និងកាតព្វកិច្ចរបាយការណ៍របស់ឥណទាយិក ដែលទទួលបានហិរញ្ញប្បទានឥណទានពីរាជរដ្ឋាភិបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រាល់ការងារបច្ចេកទេស និងប្រតិបត្តិការពាក់ព័ន្ធនឹងការឱ្យប្រាក់គេខ្ចី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៣ . _**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចនាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិក្នុងការវិនិយោគដោយ

ប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា ក្រោមទម្រង់ជាការវិនិយោគលើសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យនៃរដ្ឋបរទេស និងការវិនិយោគលើអចលកម្មហិរញ្ញវត្ថុផ្សេងៗ ។

## ជំពូកទី ៤
## ការទូទាត់សេវាបំណុលសាធារណៈ

**មាត្រា ២៤ .-**

រាល់ការទូទាត់សេវាបំណុលសាធារណៈ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងកិច្ចព្រមព្រៀងឥណទាន ។

**មាត្រា ២៥ .-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចព្យាករណ៍សេវាបំណុលសាធារណៈ ស្របតាមចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ២៦ .-**

រាល់ការទូទាត់សេវាបំណុលសាធារណៈ ត្រូវធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែការទូទាត់ដោយប្រើមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ដែលត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ។

នីតិវិធី និងយន្តការនៃការទូទាត់សេវាបំណុលសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ

**មាត្រា ២៧ .-**

យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ គឺជាក្របខ័ណ្ឌយុទ្ធសាស្ត្រ ដែលចែងអំពីគោលដៅគ្រប់គ្រងបំណុលសាធារណៈរយៈពេលមធ្យម ឬវែង របស់រាជរដ្ឋាភិបាលអនុលោមតាមបរិបទនៃក្របខ័ណ្ឌគោលនយោបាយថវិកា ស្ថានភាពបំណុលបច្ចុប្បន្ន និង

ផែនការតម្រូវការហិរញ្ញប្បទាន ដោយរក្សាហានិ៍ យ និងបន្ទុកសេវាបំណុលសាធារណៈឲ្យនៅកម្រិតអប្បបរមា ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភ ារិច្ចរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈរៀងរាល់ ៥ឆ្នាំម្តង ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈពិនិត្យយល់ព្រម មុននឹងសុំ រសម្រេចពីនាយករដ្ឋមន្ត្រី ។

យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណ អាចត្រូវបានធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ។

**មាត្រា ២៨ .-**

រាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រង ណុលសាធារណៈ ត្រូវអនុវត្តអនុលោមតាមយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ២៩ .-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារ ច្ចផ្សព្វផ្សាយជាសាធារណៈនូវខ្លឹមសារសង្ខេបនៃយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណ ៈ ។

ទម្រង់ និងខ្លឹមសារសង្ខេបនៃយុទ្ធសាស្ត្រ ប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣០ .-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចតាមដានរាល់សូចនាករសំខាន់ៗនៃបំណុលក្រៅប្រទេសនិងបំណុលសាធារណៈ និងវិភាគចីរភាពបំណុលរៀងរាល់ ២ឆ្នាំម្តង ។ ការវិភាគចីរភាពបំណុល អាចត្រូវបានធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ។

**មាត្រា ៣១ .-**

យន្តការ និងវិធីសាស្ត្រក្នុងការវិភាគចីរភាពបំណុល និងការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៦
## កិច្ចបញ្ជិកា និង ការរៀបចំរបាយការណ៍

**មាត្រា ៣២ . _**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចធ្វើកិច្ចបញ្ជិកានូវរាល់ប្រតិបត្តិការហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគណនីរតនាគារជាតិ ស្របតាមចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ។

**មាត្រា ៣៣ . _**

វិធាននៃកិច្ចបញ្ជិកាគណនេយ្យ ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៤ . _**

អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចេញផ្សាយជាផ្លូវការនូវព័ត៌មានស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ។

ទម្រង់ និងខ្លឹមសារនៃព័ត៌មានស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ៣៥ . _**

មន្ត្រីសាធារណៈគ្រប់ជាន់ថ្នាក់ ដែលត្រូវបានរកឃើញថា មិនបានគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនដែលរដ្ឋបានប្រគល់ជូន ត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ដូចមាត្រា ៣៧
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីក្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ឧបសម្ព័ន្ធ**

# សន្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុង
# អនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ

**ការខ្ចីប្រាក់ពីគេ** (Borrowing) សំដៅដល់ប្រតិបត្តិការដូចខាងក្រោម ៖

១- ការបោះផ្សាយមូលបត្ររដ្ឋ

២- ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ

៣- ការចុះកិច្ចព្រមព្រៀងឥណទានជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ឬរដ្ឋាភិបាលបរទេស ឬ ភ្នាក់ងារឥណទានរបស់រដ្ឋាភិបាលបរទេស

៤- ការចុះកិច្ចព្រមព្រៀងឥណទានជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៥- ការខ្ចីប្រាក់ពីធនាគារជាតិនៃកម្ពុជា សម្រាប់ហិរញ្ញប្បទានលើឱនភាពថវិការយៈពេលខ្លី ស្របតាមលក្ខខណ្ឌកំណត់នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

៦- ការចុះកិច្ចព្រមព្រៀងឥណទានផ្សេងទៀត ។

រាល់ការទិញជំពាក់នូវទំនិញ ឬសេវា ដែលមានរយៈពេល តិចជាងឬស្មើ ១៨០ថ្ងៃ គិតចាប់ពីថ្ងៃទិញ មិនត្រូវបានចាត់ទុកជាការខ្ចីប្រាក់ពីគេឡើយ ។

**ការគ្រប់គ្រងបំណុលសាធារណៈ** (Public Debt Management) សំដៅដល់ការគ្រប់គ្រងលើរាល់ប្រតិបត្តិការរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹង ការខ្ចីប្រាក់ពីគេ ការឲ្យប្រាក់គេខ្ចី ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋ ការបោះផ្សាយនិងការដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការធានា កាតព្វកិច្ចបំណុលជាយថាហេតុ ការទូទាត់សេវាបំណុល ការរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ ការគ្រប់គ្រងហានិភ័យ ការវិនិយោគដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា និងប្រតិបត្តិការផ្សេងទៀតពាក់ព័ន្ធនឹងបំណុលសាធារណៈ។

**កាតព្វកិច្ចបំណុលជាយថាហេតុ** (Contingent Liability) សំដៅដល់កាតព្វកិច្ចហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលក្នុងការទូទាត់សំណង ប្រសិនបើមានព្រឹត្តិការណ៍

ជាក់លាក់ណាមួយកើតឡើងនាពេលអនាគត ដូចជា ការធានា ការរ៉ាប់រង ការទូទាត់សំណងអន្តរាយ ការបង់វិភាគទានដើម្បីធានាសមាជិកភាពកម្ពុជាក្នុងអង្គការអន្តរជាតិនានា និងការផ្តល់សំណងតាមបណ្តឹងនីត្យានុកូល ។

**ការធានា** (Guarantee) សំដៅដល់កាតព្វកិច្ចទូទាត់សេវាបំណុលរបស់សហគ្រាសសាធារណៈ សហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលរាជរដ្ឋាភិបាលបានធានាសងជំនួសនូវការប្រាក់ ឬប្រាក់ដើម ឬទាំងការប្រាក់និងប្រាក់ដើម ព្រមទាំងកម្រៃពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដែលសហគ្រាសសាធារណៈ សហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ ពុំមានលទ្ធភាពបំពេញកាតព្វកិច្ចទូទាត់សេវាបំណុល ។

**ការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ** (Debt Restructuring) សំដៅដល់ ការធ្វើហិរញ្ញប្បទានឡើងវិញចំពោះបំណុលបច្ចុប្បន្ន ការបំប្លែងបំណុល ការបង្រួមបំណុល ការទូទាត់សងបំណុលមុនឥណប្រតិទាន ការរៀបចំកម្មវិធីសងបំណុលឡើងវិញ ការរំកិលបំណុល ការទិញបំណុលមកវិញ និងការដោះដូរបំណុល ដើម្បីកាត់បន្ថយបន្ទុកសេវាបំណុល និងហានិភ័យ ។ វាក្យស័ព្ទដែលប្រើសម្រាប់និយមន័យនេះត្រូវបានកំណត់ដូចខាងក្រោម ៖

- **ការបំប្លែងបំណុល** (Debt Conversion) សំដៅដល់ការដោះដូរបំណុលដើម្បីទទួលបានជាថ្នូរមកវិញនូវទុនវិនិយោគ សម្រាប់ហិរញ្ញប្បទានលើគម្រោង ឬការអនុវត្តគោលនយោបាយអាទិភាពបន្ទាន់ណាមួយ ។
- **ការបង្រួមបំណុល** (Debt Consolidation) សំដៅដល់ការបោះផ្សាយ និងដាក់លក់បំណុលថ្មី ដើម្បីហិរញ្ញប្បទានដល់ការប្រមូលទិញបំណុលបច្ចុប្បន្នមកវិញ ក្នុងគោលដៅកាត់បន្ថយចំនួនប័ណ្ណរតនាគារ ឬសញ្ញាប័ណ្ណរតនាគារ ។ ប្រតិបត្តិការនេះច្រើនប្រើនៅក្នុងទីផ្សារមូលបត្រក្នុងប្រទេស ។
- **ការទូទាត់សងមុន** (Prepayment) សំដៅដល់ការអនុវត្តសិទ្ធិក្នុងការទូទាត់សងប្រាក់ដើមមុនឥណប្រតិទានតាមតម្លៃចារឹក ឬដោយមានបន្ថែមប្រាក់ពិន័យ ដូចមានចែងក្នុងកិច្ចព្រមព្រៀងឥណទាន ។
- **ការរំកិលបំណុល** (Rolling Over) សំដៅដល់ការបោះផ្សាយ និងដាក់លក់បំណុលថ្មី សម្រាប់ទូទាត់សងបំណុលបច្ចុប្បន្នដែលដល់ឥណប្រតិទាន ។ ប្រតិបត្តិការនេះច្រើនប្រើសម្រាប់ការដាក់លក់ប័ណ្ណរតនាគារ ។
- **ការដោះដូរបំណុល** (Debt Swap) សំដៅដល់ការប្តូរពីកាតព្វកិច្ច

បំណុលមួយទៅកាតព្វកិច្ចបំណុលមួយផ្សេងទៀត ដែលមានរចនាសម្ព័ន្ធបំណុលផ្សេងគ្នា ដូចជា ៖ រូបិយប័ណ្ណ ឬអត្រាការប្រាក់ ឬឥណប្រតិទាន ។

**ការវិនិយោគ** (Investments) សំដៅដល់ការទិញសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យនៃរដ្ឋបរទេស ឬការវិនិយោគលើអចលកម្មហិរញ្ញវត្ថុផ្សេងទៀត ដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា ។

**ការឱ្យប្រាក់គេខ្ចី** (Lending and Onlending) សំដៅដល់ប្រាក់របស់រដ្ឋ ឬប្រាក់ដែលរដ្ឋខ្ចីពីគេ ឬហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍ សម្រាប់ឲ្យសហគ្រាសសាធារណៈ ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬរដ្ឋបរទេសខ្ចី ក្នុងគោលដៅជម្រុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ។

**ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** (Annual Financial Management Law) គ្រោង និងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុករបស់រដ្ឋ ។

**បំណុលក្រៅប្រទេស** (External Debt) សំដៅដល់បំណុលក្រៅប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជាដែលរួមមាន ៖ បំណុលសាធារណៈ បំណុលផ្នែកឯកជន និងបំណុលដែលរដ្ឋាភិបាលមុនមិនទាន់បានដោះស្រាយ ។

**បំណុលសាធារណៈ** (Public Debt) សំដៅដល់បំណុលរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត និងដោយមិនរាប់បញ្ចូលបំណុលដែលពុំមានការធានាពីរាជរដ្ឋាភិបាល។

**ភ្នាក់ងារគ្រប់គ្រងមូលបត្ររដ្ឋ** (Government Securities Management Agency – GSMA) សំដៅដល់ធនាគារជាតិនៃកម្ពុជាដែលធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋតាមការធ្វើប្រតិភូកម្មអំណាចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋមិនអាចជួញដូរបាន ។

**មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ** (Government Securities Management Fund – GSMF) សំដៅដល់ប្រាក់ដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាល និងប្រាក់ដែលបានមកពីស្ថាប័នឯកជន និងសាធារណៈតាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ។

**មូលបត្ររដ្ឋមិនអាចជួញដូរបាន** (Non-marketable Securities) សំដៅដល់មូលបត្រទាំងឡាយណាដែលត្រូវសងទៅឲ្យអ្នកកាន់កាប់មូលបត្រដែលបានចុះបញ្ជី ឬសន្តតិជនពេញសិទ្ធិតាមលក្ខខណ្ឌរបស់មូលបត្រនោះ ដោយស្របទៅតាមវិសាលភាព និងការកំណត់របស់ប្រកាសដែលដាក់ឲ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អ្នកកាន់កាប់មូលបត្រ ឬសន្តតិជនពេញសិទ្ធិ មានសិទ្ធិស្នើសុំការទូទាត់សង/.

មុនឥណប្រតិទាន ទៅតាមលក្ខខណ្ឌនៃមូលបត្រទាំងនោះ ។

**មូលបត្ររដ្ឋ** (Government Securities) សំដៅដល់ប័ណ្ណ សញ្ញាប័ណ្ណ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល។ មូលបត្ររដ្ឋរួមមាន ៖

១- ប័ណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ

២- សញ្ញាប័ណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ

៣- សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់ជាមួយនឹងអត្រាអតិផរណា ឬអត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ

៤- មូលបត្ររដ្ឋដែលមិនអាចជួញដូរបាន

៥- មូលបត្ររដ្ឋផ្សេងៗដទៃទៀត ដែលបោះផ្សាយស្របតាមច្បាប់អនុញ្ញាត ។

**សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ** (Sovereign Bonds) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលត្រូវបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលលើទីផ្សារអន្តរជាតិ ។

**សេវាបំណុល** (Debt Service) សំដៅដល់ការទូទាត់ប្រាក់ដើម ការប្រាក់ និងកម្រៃពាក់ព័ន្ធផ្សេងទៀតនៃកាតព្វកិច្ចបំណុល ។

**សហគ្រាសសាធារណៈ** (Public Enterprise) សំដៅដល់សហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ ។ សហគ្រាសសាធារណៈមានបេសកកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព ។